# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ:០២០/០៧ របក.អគគ**

# របាយការណ៍

## ស្តីពី

## សកម្មភាពការងារប្រចាំខែ កក្កដា ឆ្នាំ ២០០៧
## របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
## និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កក្កដា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និង មានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ ខ្លួនស្របតាម បេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផល ជាក់ស្តែងដូចខាងក្រោម ៖

### ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ក. <u>ការងាររដ្ឋបាល</u>

-ផ្ញើសៀវភៅរបាយការណ៍ជំនួយផ្នែកច្បាប់នៅកម្ពុជា ៖ ការអនុវត្ត ការយល់ឃើញ និងតម្រូវការ ជូនអ្នកពាក់ព័ន្ធ

-ផ្ញើលិខិតស្នើសុំផ្លាស់ប្តូរកំរិត និងតម្លើងកំរិតប្រាក់មុខងារដល់មន្ត្រីនៃអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់-ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ផ្ញើរបាយការណ៍ស្តីពីសមិទ្ធិផលសំខាន់ៗនៃវិស័យកំណែទម្រង់ច្បាប់ និងប្រព័ន្ធ-យុត្តិធម៌ (២០០៣-២០០៨) និងទិសដៅអនុវត្តបន្ត ជូនអ្នកពាក់ព័ន្ធ

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧ វេលាម៉ោង ១៥:០០ រសៀល

-ផ្ញើលិខិតសុំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និង តុលាការ ឆមាស ទី១ ឆ្នាំ២០០៧ ទៅក្រសួងពាក់ព័ន្ធ រួមមាន ៖ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់ ក្រសួងកិច្ចការនារី រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

-ផ្ញើលិខិតអញ្ជើញចូលរួមក្នុងបទបង្ហាញតាមរយៈវិដេអូឆ្លងឆ្លើយ (Video Conference) ស្តីពី ទស្សនាទាននៃតុលាការគំរូ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧ នៅធនាគារពិភពលោក។

## ខ. <u>ការងារកំណែទម្រង់</u>

-រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧ វេលាម៉ោង ១៥:០០ រសៀល

-រៀបចំប្រជុំការងារបច្ចេកទេសតុលាការគំរូ បទបង្ហាញតាមរយៈវិដេអូឆ្លងឆ្លើយ (Video Conference) ស្តីពីទស្សនាទាននៃតុលាការគំរូ ជាមួយ DIHR ពីដាណឺម៉ាក នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ នៅធនាគារពិភពលោក (World Bank)

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តបន្ទាយ-មានជ័យ និង ខេត្តកំពង់ធំ

-ចូលរួមប្រជុំជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ជ្រើសរើសអ្នកជំនាញ រៀបចំប្រព័ន្ធទិន្នន័យបណ្តុះបណ្តាលសិទ្ធិមនុស្ស (Human Rights Training)

-ប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ

-ចូលរួមសម្ពោធមណ្ឌលសេវាកម្មយុត្តិធម៌ នៅស្រុកទឹកផុស និងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។

## គ. <u>ផ្សេងៗ</u>

-រៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូ

-បញ្ជូនសំណើសុំជំនួយឧបត្ថម្ភពីជប៉ុន នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ជឧជ)

-
ចូលរួមជ្រើសរើសអ្នកជំនាញរៀបចំប្រព័ន្ធទិន្នន័យសម្រាប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌ (Access to Justice) គម្រោងលេខ ១.១.១

-ចូលរួមសិក្ខាសាលាសិទ្ធិទទួលបានព័ត៌មាននៅសណ្ឋាគារភ្នំពេញ រៀបចំដោយក្រសួងទំនាក់ទំនង សភា

-ទទួលជួបក្រុម Transparency International ធ្វើបទឧទ្ទេសនាមបង្ហាញពីអំពើពុករលួយក្នុង ប្រព័ន្ធតុលាការកម្ពុជា។

## ២-សន្និដ្ឋាន

ក្នុងខែ កក្កដា ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំបទបង្ហាញតាមរយៈវិដេអូឆ្លងឆ្លើយ (Viedo Conference)ស្តីពីទស្សនាទាន នៃតុលាការគំរូ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧ ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-រៀបចំកិច្ចប្រជុំស្តីពីប្រព័ន្ធសូចនាករតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-រៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៧

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅតាមបណ្តាខេត្តនានា

-បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងបញ្ជីគម្រោង តាមរយៈការប្រជុំពិភាក្សាតាមអនុក្រុម (Sub-Group/TWG)

-ពិនិត្យ កែសម្រួល Sector Manual ។

*រាជធានី ភ្នំពេញ ថ្ងៃទី ខែ សីហា ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

**ហ៊ួន សុកុល**

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង**

**ស៊ុយ ម៉ុងលាង**